# II- រាជរដ្ឋាភិបាល

## អនុក្រឹត្យ

### អនុក្រឹត្យលេខ ០៥ អនក្រ.បក

### ស្តីអំពីការបង្កើតគណៈកម្មាធិការអន្តរក្រសួងសំរបសំរួលការត្រួតពិនិត្យ គុណភាព និង សុវត្ថិភាពផលិតផល និង សេវាកម្ម

==========

### រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៥៧ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៧

### សំរេច

**មាត្រា ១ .-** ត្រូវបានបង្កើតនូវគណៈកម្មាធិការអន្តរក្រសួងមួយ សំរាប់សំរបសំរួលនូវរាល់សកម្មភាព នៃបណ្តាស្ថាប័នត្រួតពិនិត្យជាផ្លូវការ ដែលពាក់ព័ន្ធនឹងវិស័យគុណភាពនិងសុវត្ថិភាពផលិតផល និងសេវាកម្មក្នុងកិច្ចការពារអ្នកប្រើ និងភាពស្មោះត្រង់នៃកិច្ចការជំនួញ ។

**មាត្រា២ .-** សមាសភាពនៃគណៈកម្មាធិការនេះរួមមាន ៖

| | |
|---|---|
| ១.រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម | ជាប្រធាន |
| ២.រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | អនុប្រធាន |
| ៣.ប្រធាននាយកដ្ឋានពាណិជ្ជកម្ម ហិរញ្ញវត្ថុ ធនាគារ នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤.តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |

www.pheakdeylaw.com

៥.តំណាងក្រសួងសុខាភិបាល សមាជិក

៦.តំណាងក្រសួងបរិស្ថាន សមាជិក

៧.តំណាងក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៨.តំណាងក្រសួង មហាផ្ទៃ សមាជិក

តំណាងនៃក្រសួង អាចអញ្ជើញឲ្យចូលរួមក្នុងការងាររបស់គណៈកម្មាធិការ ចំពោះកិច្ចការដែលទាក់ទងនឹងសមត្ថកិច្ចរបស់ក្រសួងនោះ ប្រសិនបើមានការចាំបាច់ ។

ប្រធានមានសិទ្ធិអញ្ជើញមន្ត្រីមានសមត្ថភាពជំនាញ ក្នុងវិស័យដែលពាក់ព័ន្ធចូលរួមផងដែរ ។

មាត្រា ៣ .- គណៈកម្មាធិការនេះ ត្រូវមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលដឹកនាំដោយលេខាមួយរូប និង មានលេខារង ៥ រូបជាអ្នកជំនួយការ សំរាប់រយៈពេល ២ឆ្នាំ ដែលអាចបន្តជាថ្មីបាន ។ មន្ត្រីទាំង ៥ រូបនេះត្រូវប្រគល់ដោយស្ថាប័នដែលជាសមាជិករបស់គណៈកម្មាធិការ ។ លេខាធិការដ្ឋានអចិន្ត្រៃយ៍មានទីតាំងការិយាល័យតាំងនៅនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) នៃក្រសួងពាណិជ្ជកម្មហើយមាន ភារកិច្ចសំរួលរាល់កិច្ចការរបស់គណៈកម្មាធិការ ។

មាត្រា ៤ .- គណៈកម្មាធិការមានភារកិច្ចរៀបចំដាក់ជូនរដ្ឋមន្ត្រី នៃក្រសួងជាសមាជិក ពិនិត្យនូវ ៖

-សេចក្តីព្រាង សំរាប់ធ្វើឲ្យបានប្រសើរ នូវការបែងចែកភារកិច្ច រវាងបណ្តាក្រសួងក្នុងវិស័យកំណត់ខាងលើ និងនូវកិច្ចសំរបសំរួលនៃសកម្មភាពនានារបស់បណ្តានាយកដ្ឋាន និងនូវ ស្ថាប័នត្រួតពិនិត្យ ។

-សំណើអំពីគោលនយោបាយជាតិ ស្តីអំពីគុណភាព និងសុវត្ថិភាពនៃផលិតផលនិងសេវាកម្ម កិច្ចការពារអ្នកប្រើ និងភាពស្មោះត្រង់នៃកិច្ចការជំនួញ ។

ក្នុងក្របខ័ណ្ឌនៃភារកិច្ចទាំងពីរខាងលើ គណៈកម្មាធិការមានកិច្ចការជាក់ស្តែងដូចតទៅ៖

-ទទួលទ្វេរទាត់តាមពេលកំណត់ នូវរបាយការណ៍សកម្មភាពរបស់ស្ថាប័ន និងនាយកដ្ឋានពាក់ព័ន្ធនីមួយៗ និងផ្តល់ការណែនាំសំរាប់ធ្វើឲ្យបានប្រសើរ នូវប្រព័ន្ធជាតិនៃកិច្ចការត្រួតពិនិត្យ ។

-ទទួលនូវគំរោងការងារដែលបណ្តាស្ថាប័ន និងនាយកដ្ឋាននានាបានពាក់តែងកសាងក្នុងវិស័យផ្ទាល់របស់គេ និងលើកសំណើទាំងអស់ អំពីការអនុវត្តន៍តាមគោលការណ៍ឯកភាព ឬអំពីការសំរបសំរួលនៃសកម្មភាពទាំងឡាយនោះ ។

-លើកសំណើ និងសំរបសំរួលប្រតិបត្តិការត្រួតពិនិត្យ ជាពិសេសលើបណ្តាបញ្ហាដែលត្រូវបានប្រកាសជាអាទិភាព ហើយដែលទាក់ទងទៅនឹងស្ថាប័ន ឬនាយកដ្ឋានពាក់ពន្ធ័ទាំងអស់ ឬ ណាមួយ ។

-ពាក់តែងកសាងកម្មវិធីនៃកិច្ចបណ្តុះ ដែលអនុគ្រោះឲ្យរៀបចំបានល្អប្រសើរ នូវដំណើរការនៃបណ្តាមន្ទីរពិសោធន៍វិភាគ និងសាកល្បង ។

-ទទួលបន្ទុកនូវការផ្តើមបង្កើត និងនូវដំណើរការប្រព័ន្ធផ្តល់ដំណឹង ពីភាពអាសន្នក្នុងករណីមានគ្រោះអាសន្នធ្ងន់ធ្ងរ ចំពោះសុខភាព និងសុវត្ថិភាពនៃអ្នក[illegible] ។

-លើកសំណើគំនិតសំរាប់ជាអ[illegible]ពាលក្នុងករណីមានជំរុះសមត្ថកិច្ចដែលអាចកើតមានឡើងរវាងក្រសួងផ្សេងៗ ។

www.pheakdeylaw.com

-កសាងផ្សព្វផ្សាយនូវរបាយការណ៍ស្តីពីសកម្មភាពរបស់ខ្លួន ដែលមានលក្ខណៈជាអាទិភាពក្នុងវិស័យ ការ នៃសកម្មភាពរបស់គណៈកម្មការនានាក្នុងការការពារអ្នកប្រើប្រាស់ និងពាណិជ្ជកម្មអន្តរជាតិ ។

-ត្រូវបានគេពិគ្រោះយោបល់ លើគ្រប់សំណើព្រាងអត្ថបទស្រាវជ្រាវឲ្យបានត្រឹមត្រូវតាមការណែនាំ ជាក់ស្តែង ឬបំពេញបន្ថែមនូវបទបញ្ញត្តិដែលមានស្រាប់ ។

-អាចសាកសួរយោបល់របស់មន្ត្រីដែលពាក់ព័ន្ធ-សេដ្ឋកិច្ច ហើយជាពិសេសតំណាងអង្គការ ថ្នាក់វិជ្ជាជីវៈមន្ត្រី សមាគមតំណាងអ្នកផលិត និងតំណាងអតិថិជន ។

-ជាអ្នកធ្វើយោងនៅព្រះរាជាណាចក្រកម្ពុជា សំរាប់គណៈកម្មការ Codex Alimentarius ដែលដឹកនាំរួមដោយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ និងអង្គការសុខភាពពិភពលោក (FAO/OMS) សំរាប់អង្គការអន្តរជាតិនៃបទដ្ឋាន (ISO) ព្រមទាំងសំរាប់អង្គការអន្តរជាតិផ្សេងទៀត ដែលមានសកម្មភាពពាក់ព័ន្ធទៅនឹងការងាររបស់គណៈកម្មាធិការនេះ ។ គណៈកម្មាធិការទទួលភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ឲ្យ ។

មាត្រា ៥ .- គណៈកម្មាធិការអាចបង្កើតក្រុមការងារអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នផ្សេងៗសំរាប់ទទួលបន្ទុក ធ្វើការសិក្សាបញ្ហាជាក់លាក់ទាំងឡាយ ។ ប្រធានគណៈកម្មាធិការអាចស្នើសុំឲ្យក្រសួងពាក់ព័ន្ធ និងកិច្ចការនៃក្រុមការងារតែងតាំងអ្នកជំនាញ របស់ក្រសួងដើម្បីចូលរួមក្នុងការងារទាំងនេះ ។

អ្នកមានសមត្ថភាពជំនាញ ដែលមិនមែនស្ថិតក្នុងក្របខ័ណ្ឌក្រសួងក្រោមមាត្រា២ នៃអនុក្រឹត្យនេះអាចចូលរួមជាសមាជិកនៃក្រុមការងារ ។

ក្រុមការងារត្រូវធ្វើរបាយការណ៍ អំពីការងាររបស់ខ្លួនជូនគណៈកម្មាធិការ ហើយមានតែគណៈកម្មាធិការមួយតែប៉ុណ្ណោះ ដែលអាចធ្វើការសំរេចបាន ។

មាត្រា ៦ .- ក្នុងព្រំដែននៃភារកិច្ចរបស់ខ្លួន គណៈកម្មាធិការអាចដោះស្រាយបញ្ហានានា ស្នើដោយរាជរដ្ឋាភិបាល ដោយរដ្ឋមន្ត្រីពាក់ព័ន្ធ ដោយប្រធាន និងដោយសមាជិកនីមួយៗរបស់គណៈកម្មាធិការ ។

ប្រធានកំណត់របៀបវារៈដោយគិតជាអាទិភាព នូវសំណើរបស់រាជរដ្ឋាភិបាល ។

មាត្រា ៧ .- វិធានផ្ទៃក្នុងនៃដំណើរការរបស់គណៈកម្មាធិការ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង ។

មាត្រា ៨ .- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៩ .- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និង រដ្ឋមន្ត្រី ក្រសួងដែលមានការពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ១០ .-អនុក្រឹត្យនេះចូលជាធរមានបញ្ញត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ឹង ហួត ហ៊ុន សែន

***

www.pheakdeylaw.com